# សេចក្តីណែនាំសម្រាប់អ្នកដែលដាក់បណ្តឹងតូចតាច

— បំពេញផ្នែក 1-6 នៅទំព័រមុខនៃទម្រង់បែបបទ។

**ផ្នែក 1៖** អ្នកអាចដាក់បណ្តឹងតូចតាចរបស់អ្នកតែនៅតុលាការក្នុងតំបន់ដែលដើមចោទ ឬ ចុងចោទរស់នៅ ឬ មានកន្លែងអាជីវកម្ម ឬ ការងារប៉ុណ្ណោះ។ បណ្តឹងតូចតាចប្រឆាំងនឹងម្ចាស់ផ្ទះដែលកើតឡើងពីការជួលផ្ទះក៏អាចដាក់បាននៅកន្លែងដែលផ្ទះនោះស្ថិតនៅដែរ។ អ្នកអាចឃើញថាកាន់តែងាយស្រួលក្នុងការអនុវត្តសេចក្តីសម្រេច ដោយអនុគ្រោះចំពោះអ្នក ប្រសិនបើអ្នកដាក់បណ្តឹងតូចតាចរបស់អ្នកនៅកន្លែងដែលចុងចោទរស់នៅ ឬក៏ធ្វើការ ប៉ុន្តែអ្នកមិនត្រូវបានតម្រូវឲ្យធ្វើដូច្នោះឡើយ។ ការិយាល័យស្មៀនតុលាការីអាចប្រាប់អ្នកថាតុលាការណាបម្រើការនៅក្នុងតំបន់ណាមួយ និង ថ្លៃប៉ុន្មានដែលអ្នកត្រូវបង់ដើម្បីដាក់រឿងក្តីរបស់អ្នក។

**ផ្នែក 2៖** បុគ្គល ឬ អាជីវកម្មដែលដាក់បណ្តឹងត្រូវបានគេហៅថាដើមចោទ។

**ផ្នែក 3៖** បញ្ចូលឈ្មោះរបស់ចុងចោទ និង អាសយដ្ឋានផ្ញើសំបុត្រ។ បុគ្គល ឬ អាជីវកម្មដែលត្រូវបានគេប្តឹងត្រូវបានគេហៅថាចុងចោទ។ ប្រសិនបើអ្នកកំពុងប្តឹងអាជីវកម្មដែលមិនមែនជាសាជីវកម្ម អ្នកគួរដាក់ឈ្មោះម្ចាស់ដែលធ្វើអាជីវកម្មនោះ នៅពីក្រោមឈ្មោះអាជីវកម្មនោះ; ឈ្មោះរបស់ម្ចាស់អាចទទួលបានពីស្មៀនទីក្រុង ឬ ក្រុង ដែលការិយាល័យអាជីវកម្មស្ថិតនៅ។ ប្រសិនបើអ្នកកំពុងប្តឹងអាជីវកម្មដែលជាសាជីវកម្ម អ្នកត្រូវតែមានឈ្មោះតាមផ្លូវច្បាប់ជាក់លាក់របស់គេ។ អ្នកអាចរកព័ត៌មាននេះពីផ្នែកកំណត់ត្រាសាជីវកម្ម នៃការិយាល័យរបស់លេខាធិការរដ្ឋ អាសយដ្ឋាន One Ashburton Place, Room 1712, Boston, MA 02108 (ឬ តាមបណ្តាញអ៊ីនធឺណិត http://corp.sec.state.ma.us/corp/corpsearch/corpsearchinput.asp)។

**ផ្នែក 4៖** បំពេញចំនួនដែលអ្នកកំពុងប្តឹងទាមទារ និង ពន្យល់ដោយសង្ខេបអំពីបណ្តឹងរបស់អ្នក។ ថ្លែងអំពីបណ្តឹងរបស់អ្នកឲ្យច្បាស់ ដូច្នេះចុងចោទអាចយល់ពីមូលហេតុដែលគេត្រូវបានប្តឹង។ ថ្លែងជាពិសេសនូវចំនួនទាំងឡាយដែលបានទាមទារសម្រាប់ការខូចខាត, សម្រាប់ការខូចខាតច្រើន ឬ ការពិន័យតាមច្បាប់, សម្រាប់ថ្លៃមេធាវី ឬ សម្រាប់សោហ៊ុយផ្សេងៗ (រួមបញ្ចូលទាំងចំនួននៃថ្លៃដាក់បណ្តឹង) ព្រមទាំងចំនួនសរុបដែលចង់បាន ដោយមិនរាប់បញ្ចូល ការប្រាក់មុនការវិនិច្ឆ័យទាំងឡាយដែលចង់បានពីតុលាការ ដោយអនុលោមតាមឧបញ្ញត្តិ។ ប្រសិនបើបណ្តឹងរបស់អ្នកបានកើតឡើងក្នុងពេលធ្វើជំនួញ ឬ ពាណិជ្ជកម្ម ឬក៏ប្រសិនបើបណ្តឹងរបស់អ្នកបានកើតឡើងក្នុងពេលអ្នកធ្វើជំនួញ ឬ ពាណិជ្ជកម្ម ឬក៏អ្នកកំពុងធ្វើបណ្តឹងចំពោះបំណុលដែលបានចាត់ឲ្យទារ សូមបញ្ជាក់ផងដែរនូវ៖ (1) ឈ្មោះរបស់ម្ចាស់បំណុលដើម (ប្រសិនបើផ្សេងពីអ្នក), (2) តែលេខគណនីបួនខ្ទង់ចុងក្រោយណាមួយដែលបានកំណត់ដោយម្ចាស់បំណុលដើម ព្រមទាំងចំនួន និង កាលបរិច្ឆេទនៃការសងប្រាក់ចុងក្រោយ ប្រសិនបើមាន។ ចុះហត្ថលេខាឈ្មោះរបស់អ្នកក្នុងចន្លោះដែលបានផ្តល់ឲ្យ។

**ផ្នែក 5៖** បញ្ជាក់ថាតើអ្នកកំពុងប៉ុនប៉ងសម្រុះសម្រួលបណ្តឹងនេះដែរឬទេ។

**ផ្នែក 6៖** ប្រសិនបើអ្នកស្គាល់លេខសន្តិសុខសង្គមរបស់ចុងចោទ អ្នកអាចកំណត់ថាតើគេកំពុងបំពេញភារកិច្ចយោធាដែរឬអត់ តាមបណ្តាញអ៊ីនធឺណិត www.dmdc.osd.mil/scra/owa/home; បើមិនដូច្នោះទេ អ្នកត្រូវតែសរសេរទៅទីស្នាក់ងារសេវាយោធាដែលសមស្រប (ដែលបានរាយនៅ www.defenselink.mil/faq/pis/PC09SLDR.html)។ ប្រសិនបើអ្នកមិនអាចកំណត់ថាតើចុងចោទកំពុងបំពេញភារកិច្ចយោធាដែរឬអត់ ហើយចុងចោទមិនអាចមកបង្ហាញខ្លួន តុលាការអាចតម្រូវឲ្យអ្នកដាក់ប្រាក់ធានា ឬ អាចចេញបញ្ជាផ្សេងទៀតដើម្បីការពារសិទ្ធិរបស់ចុងចោទ ប្រសិនបើគេកំពុងបំពេញភារកិច្ចយោធា។ យក ឬ ផ្ញើទម្រង់បែបបទដែលបានបំពេញគ្រប់ផ្នែក អមជាមួយនឹងមូលប្បទានបត្រ ឬ ប័ណ្ណបញ្ជាបង់ប្រាក់ (ដោយបង់ទៅឲ្យ "ស្មៀនតុលាការី") សម្រាប់ថ្លៃដាក់បណ្តឹង ទៅការិយាល័យស្មៀនតុលាការីរបស់តុលាការដែលអ្នកដាក់រឿងក្តីរបស់អ្នក។ **ប្រសិនបើបណ្តឹងរបស់អ្នកបានកើតឡើងក្នុងពេលអ្នកធ្វើជំនួញ ឬ ពាណិជ្ជកម្ម ឬក៏អ្នកកំពុងធ្វើបណ្តឹងទារបំណុលដែលបានចាត់ឲ្យទារ** អ្នកក៏ត្រូវដាក់ទម្រង់បែបបទ "ការផ្ទៀងផ្ទាត់អាសយដ្ឋានរបស់ចុងចោទ" ជាមួយបណ្តឹងរបស់អ្នកផងដែរ ដោយបញ្ជាក់ថាអ្នកបានផ្ទៀងផ្ទាត់អាសយដ្ឋានផ្ញើសំបុត្ររបស់ចុងចោទក្នុងលក្ខណៈដែលបានថ្លែងក្នុងទម្រង់



(

This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

បែបបទនោះ។ ប្រសិនបើអ្នកមិនធ្វើដូច្នោះទេ ហើយចុងចោទមិនអាចមកបង្ហាញខ្លួន អ្នកប្រហែលជាមិនអាចទទួលការវិនិច្ឆ័យកំបាំងមុខឡើយ ហើយបណ្តឹងរបស់អ្នកនឹងត្រូវបានលើកចោលដោយមិនបាត់បង់សិទ្ធិ។ (តម្រូវការនេះមិនអនុវត្តទេ ប្រសិនបើបណ្តឹងរបស់អ្នកបានកើតឡើងពីការជួលទីលំនៅរបស់អ្នកដែលមានបីបន្ទប់ ឬក៏តិចជាងនេះ ដែលនោះក៏ជាទីលំនៅចម្បងរបស់អ្នកដែរ លុះត្រាតែអ្នកជាម្ចាស់ផង, ជាអ្នកគ្រប់គ្រងផង ឬក៏ជាប់ពាក់ព័ន្ធនឹងការជួលទីលំនៅផ្សេងទៀត។)

## សេចក្តីណែនាំចំពោះដើមចោទ និង ចុងចោទ

1. **អ្វីជាបណ្តឹងតូចតាច?** តុលាការបណ្តឹងតូចតាចត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបណ្តឹងប្រាក់តូចតាច ដែលធ្វើឲ្យកាន់តែងាយស្រួល និង មិនសូវថ្លៃចំពោះសាធារណជនក្នុងការប្រើតុលាការ។ ដើមចោទដែលមានឈ្មោះនៅទំព័រមុខនៃទម្រង់បែបបទនេះបានដាក់បណ្តឹងតូចតាចប្រឆាំងនឹងចុងចោទ ទាមទារចំនួនទឹកប្រាក់ និង មូលហេតុដែលបានថ្លែង។ ភាគីទាំងពីរត្រូវតែបង្ហាញខ្លួននៅតុលាការ នៅថ្ងៃ និង ពេលវេលាកាត់ក្តី ដែលបានបង្ហាញនៅខាងមុខនៃទម្រង់បែបបទនេះ លុះត្រាតែដើមចោទ និង ចុងចោទដោះស្រាយវិវាទនេះមុនពេលនោះ។

2. **តើចុងចោទបានទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងនេះដូចម្តេច?** ចុងចោទត្រូវបានផ្ញើនូវឯកសារចម្លងនៃ “សេចក្តីថ្លែងការណ៍អំពីបណ្តឹង និង សេចក្តីជូនដំណឹងអំពីការកាត់ក្តី” នេះ តាមសំបុត្រថ្នាក់ទីមួយ។ ជាធម្មតា ច្បាប់ទូទៅ c. 223A, § 6 តម្រូវឲ្យចុងចោទដែលនៅក្រៅរដ្ឋទទួលសេចក្តីជូនដំណឹងរបស់ពួកគេតាមសំបុត្រដែលមានការបញ្ជាក់ ជាមួយនឹងការត្រឡប់មកវិញនូវបង្កាន់ដៃទទួល។ ប្រសិនបើដើមចោទសួរ តុលាការនឹងជូនដំណឹងដើមចោទថាតើសេវាប្រៃសណីយ៍អាចជូនដំណឹង ("បម្រើជូន") ចុងចោទដែរឬអត់។

3. **តើត្រូវការមេធាវីដែរឬទេក្នុងតុលាការបណ្តឹងតូចតាច?** ទេ ប៉ុន្តែអ្នកអាចជួលម្នាក់ ប្រសិនបើអ្នកចង់។

4. តើមាន “សោហ៊ុយ” អ្វីខ្លះ? ប្រសិនបើដើមចោទឈ្នះក្តី ឬ ប្រសិនបើភាគីទាំងពីរដោះស្រាយបណ្តឹង ដើមចោទប្រហែលជាអាចទារពីចុងចោទមកវិញនូវ “សោហ៊ុយ” នៃថ្លៃដាក់ពាក្យបណ្តឹងនៅតុលាការ និង ថ្លៃប្រៃសណីយ៍។

5. **តើចុងចោទត្រូវបានតម្រូវឲ្យដាក់ចម្លើយដែរឬទេ?** ចុងចោទមិនត្រូវបានតម្រូវឲ្យដាក់ចម្លើយជាលាយលក្ខណ៍អក្សរចំពោះបណ្តឹងរបស់ដើមចោទទេ។ ទោះជាយ៉ាងនេះក្តី ចុងចោទអាចផ្ញើលិខិតដែលមានចុះហត្ថលេខាជូនតុលាការ ជាមួយនឹងឯកសារចម្លងមួយច្បាប់ទៅដើមចោទ ដោយថ្លែងយ៉ាងច្បាស់ និង សាមញ្ញពីមូលហេតុដែលដើមចោទមិនអាចឈ្នះក្តី។

6. **ចុះប្រសិនបើចុងចោទយល់ថាដើមចោទជាអ្នកជំពាក់ប្រាក់គាត់វិញ?** នៅក្នុងចម្លើយរបស់គេ ឬ ក្នុងលិខិតដាច់ដោយឡែកជូនតុលាការ ឬក៏នៅថ្ងៃកាត់ក្តី ចុងចោទអាចថ្លែងជាលាយលក្ខណ៍អក្សរ ដោយចម្លងឯកសារមួយច្បាប់ជូនដើមចោទ នូវបណ្តឹងទាមទារប្រាក់ពីដើមចោទ ដោយស្ថិតនៅក្នុងយុត្តាធិការនៃតុលាការបណ្តឹងតូចតាចនេះ (“បណ្តឹងតប”)។ បណ្តឹងទាំងពីរនឹងត្រូវបានចាត់ទុកថាជារឿងក្តីតែមួយ និង កាត់ក្តីជាមួយគ្នា ប្រសិនបើចុងចោទផ្ញើតាមប្រៃសណីយ៍នូវឯកសារចម្លងនៃបណ្តឹងតបរបស់គេជូនដើមចោទ យ៉ាងហោចណាស់ដប់ថ្ងៃ មុនថ្ងៃកាត់ក្តីដែលបានគ្រោង ឬក៏ប្រសិនបើតុលាការបញ្ជាឲ្យចាត់ទុកពួកវាដូច្នោះ។ បណ្តឹងតបនោះមិនមែនខានមិនបានឡើយ។

7. **ចុះប្រសិនបើចុងចោទព្រមទទួលថាជំពាក់ប្រាក់ទាំងអស់?** ចុងចោទគួរទាក់ទងដើមចោទ និង រៀបចំធ្វើការសងប្រាក់។ ប្រសិនបើមិនបានសងប្រាក់ មុនកាលបរិច្ឆេទកាត់ក្តីទេ ទាំងដើមចោទ និង ចុងចោទត្រូវតែបង្ហាញខ្លួនក្នុងតុលាការ ឬក៏ដាក់នៅតុលាការនូវទម្រង់បែបបទ “កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសងប្រាក់” ផ្លូវការ។ ទម្រង់បែបបទនោះរាយប្រភពចំណូលដែលបានលើកលែងពីការបញ្ជាឲ្យសងប្រាក់ទាំងឡាយ។

8. **ចុះប្រសិនបើចុងចោទព្រមទទួលថាជំពាក់ប្រាក់ ប៉ុន្តែត្រូវការពេលដើម្បីសង?** ប្រសិនបើដើមចោទ និង ចុងចោទព្រមព្រៀងគ្នាអំពីគម្រោងសំណងដែលបានលើកឡើង ពួកគេត្រូវដាក់នៅតុលាការនូវទម្រង់បែបបទ “កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសង



This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

ប្រាក់" ផ្លូវការ។ ប្រសិនបើនេះមិនបានធ្វើឡើងមុនថ្ងៃកាត់ក្តីទេ ទាំងដើមចោទ និង ចុងចោទត្រូវតែបង្ហាញខ្លួនក្នុងតុលាការនៅថ្ងៃនោះ។ ចុងចោទត្រូវតែបំពេញទម្រង់បែបបទ "របាយការណ៍ហិរញ្ញវត្ថុ" និង ផ្តល់មូលហេតុរបស់គេក្នុងការស្នើសុំពន្យារពេលដើម្បីសង។

9. **ចុះប្រសិនបើចុងចោទយល់ថាគាត់មិនជំពាក់អ្វីទាំងអស់ ឬ ជំពាក់តែប្រាក់ខ្លះដែលបានប្តឹងនោះ?** ចុងចោទត្រូវតែបង្ហាញខ្លួនក្នុងតុលាការនៅថ្ងៃកាត់ក្តី និង អាចសួរថាតើគេជំពាក់លុយមែនឬទេ ហើយប្រសិនបើដូច្នោះ ប៉ុន្មាន។

10. **ចុះប្រសិនបើខ្ញុំមិនអាចមកតុលាការនៅថ្ងៃកាត់ក្តី?** អ្នកគួរហៅទូរស័ព្ទ ឬ សរសេរទៅបុគ្គលនៅភាគីម្ខាងទៀត និង សុំគេឲ្យយល់ព្រមពន្យារពេល ("លើកពេល") រឿងក្តី។ ការលើកពេលគួរតែធ្វើឡើងដោយមានមូលហេតុល្អប៉ុណ្ណោះ ដូចជាមានជំងឺ, ការសង្រ្គោះបន្ទាន់ ឬក៏សាក្សីមិនទំនេរ។ អ្នកត្រូវតែសរសេរលិខិតជូនស្មៀនតុលាការីនៃតុលាការដោយសុំឲ្យតុលាការផ្តល់ជូនអ្នកនូវការលើកពេល មិនថាអ្នកអាចទាក់ទងបុគ្គលនៅភាគីម្ខាងទៀតឬក៏អត់ឡើយ និង មិនថាភាគីទាំងពីរយល់ព្រមឲ្យលើកពេល ឬក៏អត់ឡើយ។ ចូរកុំរង់ចាំរហូតដល់នាទីចុងក្រោយ។ ប្រសិនបើភាគីម្ខាងទៀតធ្វើសំណើសមហេតុផលសម្រាប់ការលើកពេល វាអាចបង្ការជូនអ្នកនូវទំនាស់ខ្លះ ប្រសិនបើអ្នកយល់ព្រមចំពោះសំណើ។

11. **ចុះប្រសិនបើខ្ញុំមិនមកតុលាការនៅថ្ងៃកាត់ក្តី?** ប្រសិនបើចុងចោទមិនមកបង្ហាញខ្លួនសម្រាប់ការកាត់ក្តី ហើយដើមចោទមកបង្ហាញខ្លួន តុលាការអាចធ្វើការវិនិច្ឆយកំបាំងមុខ និង បញ្ជាឲ្យចុងចោទសងចំនួនដែលបានប្តឹងទាមទារ។ តុលាការីអាចសុំឲ្យដើមចោទបង្ហាញព័ស្តុតាងខ្លះនៃបណ្តឹងសូម្បីតែចុងចោទមិនមានវត្តមានក៏ដោយ។ ប្រសិនបើដើមចោទមិនមកបង្ហាញខ្លួនសម្រាប់ការកាត់ក្តី ហើយចុងចោទមកបង្ហាញខ្លួន តុលាការនឹងធ្វើការវិនិច្ឆយឲ្យចុងចោទ។ ប្រសិនបើទាំងដើមចោទ និង ចុងចោទមិនមកបង្ហាញខ្លួនសម្រាប់ការកាត់ក្តី បណ្តឹងនោះនឹងត្រូវលើកចោល។

12. **តើខ្ញុំត្រូវត្រៀមខ្លួនសម្រាប់ការកាត់ក្តីដូចម្តេច?** វាអាចមានប្រយោជន៍ក្នុងការសរសេរជាមុននូវអង្គហេតុនៃរឿងក្តីនេះតាមលំដាប់លំដោយដែលបានកើតឡើង។ នេះនឹងជួយអ្នករៀបចំគំនិតរបស់អ្នក និង ធ្វើបទបង្ហាញច្បាស់លាស់អំពីសាច់រឿងរបស់អ្នក។ នៅថ្ងៃកាត់ក្តី អ្នកត្រូវតែនាំមកជាមួយអ្នកនូវសាក្សីទាំងឡាយ, មូលប្បទានបត្រ, វិក្កយបត្រ, ឯកសារ, រូបថត ឬ លិខិតដែលនឹងជួយអ្នកបង្ហាញព័ស្តុតាងនៃរឿងក្តីរបស់អ្នក។ ប្រសិនបើអ្នកត្រូវការឲ្យសាក្សីមកតុលាការ ប៉ុន្តែសាក្សីមិនមក សូមសុំឲ្យស្មៀននៅការិយាល័យរបស់តុលាការីចេញដីកាកោះហៅសាក្សី ដែលបន្ទាប់មក អ្នកត្រូវតែរៀបចំឲ្យមន្ត្រីប្រគល់ជូនសាក្សី។ អ្នកប្រហែលជាត្រូវការសាក្សីជំនាញដើម្បីបញ្ជាក់ពីបញ្ហាខ្លះដែលមិនមែនស្ថិតនៅក្នុងបទពិសោធន៍ទូទៅ។ ដើមចោទត្រូវតែបញ្ជាក់ថាបណ្តឹងនោះគឺជាបណ្តឹងមួយដែលច្បាប់ទទួលស្គាល់ និង ថាចុងចោទជាអ្នកទទួលខុសត្រូវ បើមិនដូច្នោះទេ តុលាការីនឹងធ្វើសេចក្តីសម្រេចសម្រាប់ចុងចោទ។

13. **តើនឹងមានអ្វីកើតឡើងនៅថ្ងៃកាត់ក្តី?** ត្រូវប្រាកដថាមកឲ្យទាន់ពេល។ ប្រសិនបើរឿងក្តីរបស់អ្នកមិនបានដោះស្រាយដោយអ្នកសម្រុះសម្រួលទេ ការកាត់ក្តីនឹងធ្វើឡើងនៅចំពោះមុខតុលាការី។ ដើមចោទនឹងត្រូវបានសុំឲ្យប្រាប់ភាគីរបស់គេនូវសាច់រឿងនោះ រួចហើយចុងចោទនឹងប្រាប់ភាគីរបស់គេ។ ភាគីនីមួយៗនឹងមានឱកាសសួរសំណួរដល់ភាគីម្ខាងទៀត និង សាក្សីរបស់ភាគីម្ខាងទៀត។ ដើម្បីឈ្នះក្តី ច្បាប់តម្រូវឲ្យដើមចោទបញ្ជាក់អំពីសុពលភាពនៃបណ្តឹងរបស់គេ។

14. **តើតុលាការីនឹងធ្វើអ្វីខ្លះ?** តុលាការីនឹងធ្វើសេចក្តីសម្រេច។ សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេច (ដែលគេហៅថា "ការវិនិច្ឆយ") នឹងផ្តល់ជូន ឬ ផ្ញើជូនភាគីនីមួយៗ។

15. **តើខ្ញុំអាចប្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់តុលាការីដែរឬទេ?** ដោយការដាក់បណ្តឹងនៅតុលាការបណ្តឹងតូចតាច ដើមចោទ (និង ចុងចោទ នៅពេលមានបណ្តឹងតប) បោះបង់សិទ្ធិក្នុងការឲ្យគណៈវិនិច្ឆយសម្រេចលើបណ្តឹង និង ប្តឹងសាទុក្ខ ប្រសិនបើគេចាញ់ក្តី។ ប្រសិនបើចុងចោទចាញ់ក្តី (ឬ ដើមចោទចាញ់ក្តីលើបណ្តឹងតបណាមួយ) នៅចំពោះមុខតុលាការី គេអាចប្តឹងសាទុក្ខសម្រាប់ការកាត់ក្តីថ្មីដោយចៅក្រម ឬ គណៈវិនិច្ឆយលើបញ្ហាជម្លោះនៃអង្គហេតុណាមួយ ប៉ុន្តែត្រូវតែដាក់ប្រាក់ធានាមួយ លុះត្រាតែតម្រូវការនេះត្រូវបានលើកលែង។ (Rev. 10/09)



Text
This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

## ព័ត៌មានអំពីការវិនិច្ឆ័យលើបណ្ដឹងតូចតាចនេះ

រឿងក្ដីបណ្ដឹងតូចតាចរបស់អ្នកត្រូវបានចេញសេចក្ដីសម្រេច។ **ការវិនិច្ឆ័យ** (សេចក្ដីសម្រេច) របស់តុលាការ, ចៅក្រម ឬ គណៈវិនិច្ឆ័យត្រូវបានភ្ជាប់មកជាមួយ។ **ម្ចាស់បំណុលនៃការវិនិច្ឆ័យ**គឺជាបុគ្គល (ឬ អាជីវកម្ម) ដែលបានឈ្នះក្ដី ហើយមានសិទ្ធិប្រមូលប្រាក់។ **កូនបំណុលនៃការវិនិច្ឆ័យ**គឺជាបុគ្គល (ឬ អាជីវកម្ម) ដែលបានចាញ់ក្ដី និង ជាអ្នកជំពាក់ប្រាក់។ ពាក្យ **បណ្ដឹង** មានន័យថា បណ្ដឹងសម្រាប់ការខូចខាតប្រាក់។ សម្រាប់ព័ត៌មានបន្ថែម សូមមើលច្បាប់ទូទៅរបស់រដ្ឋម៉ាសាជូសេត ជំពូក 218 មាត្រា 21-25 (www.mass.gov/legis/laws/mgl/218-21.htm) និង វិធានតុលាការកាត់ក្ដី III, វិធានបណ្ដឹងតូចតាចឯករូប (www.mass.gov/courts/districtcourt)។ ឯកសារទាំងនេះមាននៅបណ្ណាល័យសាធារណៈ ឬ បណ្ណាល័យច្បាប់នានា។

## ប្រសិនបើអ្នកឈ្នះក្ដីនៅចំពោះមុខតុលាការ

***ប្រសិនបើអ្នកត្រូវបានប្ដឹងដោយភាគីម្ខាងទៀត ហើយបានឈ្នះក្ដី*** ភាគីម្ខាងទៀតមិនអាចប្ដឹងសាទុក្ខលើសេចក្ដីសម្រេចរបស់តុលាការ ដោយអនុគ្រោះចំពោះអ្នកឡើយ។ ***ប្រសិនបើអ្នកបានប្ដឹងភាគីម្ខាងទៀត និង បានឈ្នះក្ដី*** ហើយតុលាការបានកាត់ឲ្យអ្នកទទួលប្រាក់ អ្នកមិនអាចប្រមូលប្រាក់នោះឡើយ លុះត្រាតែពេលឲ្យកូនបំណុលនៃការវិនិច្ឆ័យប្ដឹងសាទុក្ខបានផុតកំណត់ ឬ រហូតទាល់តែបណ្ដឹងសាទុក្ខត្រូវបានចេញសេចក្ដីសម្រេច។ ប្រសិនបើកូនបំណុលនៃការវិនិច្ឆ័យមិនប្ដឹងសាទុក្ខទេ ឬ ប្រសិនបើអ្នកឈ្នះក្ដីម្ដងទៀតនៅពេលប្ដឹងសាទុក្ខ ខាងក្រោមគឺជាជំហានខ្លះដែលអ្នកអាចធ្វើដើម្បីប្រមូលប្រាក់របស់អ្នក។ នៅពេលអ្នកបានប្រមូលសំណងនៃការវិនិច្ឆ័យគ្រប់ចំនួន អ្នកត្រូវតែជូនដំណឹងការិយាល័យស្មៀនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 10 ថ្ងៃ។ អ្នកមិនត្រូវបានតម្រូវឲ្យប្រើទម្រង់បែបបទជាក់លាក់ណាមួយឡើយ ប៉ុន្ដែទម្រង់បែបបទ *សេចក្ដីជូនដំណឹងអំពីការជម្រះបំណុល* អាចរកបាននៅការិយាល័យរបស់ស្មៀនសម្រាប់គោលបំណងនេះ។

1. **សុំសំណង** សុំឲ្យកូនបំណុលនៃការវិនិច្ឆ័យសងប្រាក់ ឬ ប្រគល់ទ្រព្យសម្បត្តិមកវិញ តាមការបញ្ជារបស់តុលាការ។
2. **សវនាការសំណង** ប្រសិនបើតុលាការបានរៀបគម្រោងសវនាការសំណង ហើយកូនបំណុលនៃការវិនិច្ឆ័យមិនសងប្រាក់មុនសវនាការនោះទេ តុលាការនឹងពិនិត្យមើលលទ្ធភាពរបស់កូនបំណុលនៃការវិនិច្ឆ័យក្នុងការសងប្រាក់ ហើយអាចបញ្ជាឲ្យសងប្រាក់ភ្លាមៗ ឬ ធ្វើគម្រោងសំណង។ បន្ទុកគឺធ្លាក់លើអ្នកក្នុងការបង្ហាញថាកូនបំណុលនៃការវិនិច្ឆ័យអាចសងប្រាក់ដោយមិនប្រើចំណូលដែលបានលើកលែងដោយច្បាប់។ អ្នកអាចពិនិត្យមើលទម្រង់បែបបទ *របាយការណ៍ហិរញ្ញវត្ថុរបស់កូនបំណុលនៃការវិនិច្ឆ័យ* របស់គេ និង បង្ហាញព័ត៌មានទាំងឡាយជូនតុលាការ ដែលពាក់ព័ន្ធនឹងលទ្ធភាពរបស់កូនបំណុលនៃការវិនិច្ឆ័យក្នុងការសង។ ប្រសិនបើតុលាការកំណត់ថាកូនបំណុលនៃការវិនិច្ឆ័យមិនមានលទ្ធភាពខាងហិរញ្ញវត្ថុក្នុងការសងប្រាក់ឥឡូវទេ អ្នកអាចស្នើឲ្យតុលាការរៀបគម្រោងត្រួតពិនិត្យបញ្ហានោះ នៅថ្ងៃក្រោយ។
3. **សេចក្ដីជូនដំណឹងឲ្យបង្ហាញមូលហេតុ** ប្រសិនបើតុលាការមិនបានរៀបគម្រោងសវនាការសំណងទេ ហើយកូនបំណុលនៃការវិនិច្ឆ័យមិនសងប្រាក់នោះ សូមសុំឲ្យការិយាល័យស្មៀនចេញឲ្យអ្នកនូវ *សេចក្ដីជូនដំណឹងឲ្យបង្ហាញមូលហេតុ* ដែលតម្រូវឲ្យកូនបំណុលនៃការវិនិច្ឆ័យបង្ហាញខ្លួននៅចំពោះមុខតុលាការ។ អ្នកត្រូវតែនៅតុលាការដែរនៅថ្ងៃនោះ។ អ្នកត្រូវតែបង់ថ្លៃជូនតម្រួតក្រុង ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់របស់ខោនធីឲ្យចាត់ការទម្រង់បែបបទនេះលើកូនបំណុលនៃការវិនិច្ឆ័យ ប៉ុន្ដែចំនួននោះនឹងត្រូវបន្ថែមទៅលើចំនួនដែលកូនបំណុលនៃការវិនិច្ឆ័យជំពាក់។
4. **ដីកាចាប់ខ្លួន (ដីកាចាប់ខ្លួនខាងរដ្ឋប្បវេណី)** ប្រសិនបើកូនបំណុលនៃការវិនិច្ឆ័យមិនបង្ហាញខ្លួននៅសវនាការសំណង តាមការបញ្ជាទេ ឬ បន្ទាប់ពីបានឲ្យ *សេចក្ដីជូនដំណឹងឲ្យបង្ហាញមូលហេតុ* សូមសុំឲ្យការិយាល័យស្មៀនរបស់តុលាការចេញឲ្យអ្នកនូវ *ដីកាចាប់ខ្លួន* (ដីកាចាប់ខ្លួនខាងរដ្ឋប្បវេណី) កូនបំណុលនៃការវិនិច្ឆ័យ។ អ្នកត្រូវតែបង់ថ្លៃជូនតម្រួត ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់របស់ខោនធី ដើម្បីចាប់កូនបំណុលនៃការវិនិច្ឆ័យ និង នាំគេមកតុលាការ ប៉ុន្ដែចំនួននោះនឹងបន្ថែមទៅលើអ្វីដែលកូនបំណុលនៃការវិនិច្ឆ័យជំពាក់។ សូមឲ្យលេខទូរស័ព្ទពេលថ្ងៃរបស់អ្នកទៅតម្រួត ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់របស់ខោនធី និង សុំឲ្យគេទាក់ទងអ្នក នៅពេលនាំខ្លួនកូនបំណុលនៃការវិនិច្ឆ័យទៅតុលាការ។
5. **ដីកាអនុវត្តសាលក្រម** ប្រសិនបើអ្នកអាចដឹងពីទ្រព្យសម្បត្តិរបស់កូនបំណុលនៃការវិនិច្ឆ័យ (អចលនទ្រព្យ, យានយន្ត។ល។) ដែលអាចរឹបអូស និង លក់ដើម្បីសងចំពោះការវិនិច្ឆ័យរបស់អ្នក បន្ទាប់ពីសវនាការសំណង សូមសុំឲ្យការិយាល័យស្មៀនចេញឲ្យអ្នកនូវ *ដីកាអនុវត្តសាលក្រម*។ ប្រសិនបើមិនបានរៀបគម្រោងសវនាការសំណងទេ អ្នកអាចសុំ *ដីកាអនុវត្តសាលក្រម* ក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការវិនិច្ឆ័យ។ អ្នកត្រូវតែផ្ដល់ *ដីកាអនុវត្តសាលក្រម* ជូនតម្រួត ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់របស់ខោនធីឲ្យរឹបអូស និង លក់ទ្រព្យសម្បត្តិរបស់កូនបំណុលនៃការវិនិច្ឆ័យ ដើម្បីសង


This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

ចំពោះការវិនិច្ឆ័យ។

***ប្រសិនបើអ្នកបានប្តឹងភាគីម្ខាងទៀត និង បានចាញ់ក្តី*** ហើយតុលាការីមិនកាត់ក្តីឲ្យអ្នកទទួលប្រាក់ សេចក្តីសម្រេចនោះគឺចុងក្រោយ។ អ្នកបានចាញ់ក្តីរបស់អ្នក ហើយភាគីម្ខាងទៀតមិនចាំបាច់សងអ្នកអ្វីទាំងអស់។ អ្នក***មិន***អាចប្តឹងសាទុក្ខពីសេចក្តីសម្រេចរបស់តុលាការីប្រឆាំងនឹងអ្នកឡើយ។ ***ប្រសិនបើអ្នកត្រូវបានប្តឹងដោយភាគីម្ខាងទៀត និង បានចាញ់ក្តី*** ហើយតុលាការីបានបញ្ជាឲ្យអ្នកសងប្រាក់ជូនភាគីម្ខាងទៀត អ្នកត្រូវធ្វើកិច្ចការមួយក្នុងចំណោមកិច្ចការបួនខាងក្រោម៖

1. **សងការវិនិច្ឆ័យគ្រប់ចំនួន ក្នុងរយៈពេល 30 ថ្ងៃ** អ្នកត្រូវតែសងការវិនិច្ឆ័យគ្រប់ចំនួន ប្រសិនបើអ្នកមានលទ្ធភាពខាងហិរញ្ញវត្ថុក្នុងការធ្វើដូច្នោះ។ អ្នក**មិន**ត្រូវបានតម្រូវឲ្យសងការវិនិច្ឆ័យពីចំណូលដែលបានលើកលែងដោយច្បាប់ឡើយ។ ប្រសិនបើអ្នកមិនសងចំនួនដែលបានបញ្ជាទេ ហើយអ្នកមានលទ្ធភាពធ្វើដូច្នោះ អ្នកអាចត្រូវបានចាត់ទុកថាមិនគោរពតុលាការ និង អាចជាប់ពន្ធនាគារ ឬក៏ត្រូវបង់សោហ៊ុយបន្ថែម។ សងប្រាក់គ្រប់ចំនួនដោយផ្ទាល់ជូនម្ចាស់បំណុលនៃការវិនិច្ឆ័យ លុះត្រាតែតុលាការីបានបញ្ជាផ្សេងពីនេះ។ ប្រសិនបើតុលាការីបានបញ្ជាអ្នកឲ្យប្រគល់ទ្រព្យជូនម្ចាស់បំណុលនៃការវិនិច្ឆ័យវិញ អ្នកត្រូវតែធ្វើដូច្នោះ។ កូនបំណុលនៃការវិនិច្ឆ័យត្រូវតែជូនដំណឹងដល់តុលាការជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីការវិនិច្ឆ័យត្រូវបានសងគ្រប់ចំនួន។ អ្នកត្រូវប្រាកដថាធ្វើដូច្នេះ ដើម្បីការពារកំណត់ត្រាកិត្តិយសរបស់អ្នក។ ប្រសិនបើម្ចាស់បំណុលនៃការវិនិច្ឆ័យបដិសេធក្នុងការធ្វើដូច្នេះ អ្នកអាចសុំឲ្យតុលាការធ្វើការកំណត់ដូចនោះលើកំណត់ត្រាឯកសាររឿងក្តី។

2. **សុំឲ្យតុលាការីកំណត់គម្រោងសំណង** *ប្រសិនបើតុលាការីបានរៀបគម្រោងសវនាការសំណង* នៅក្នុងសវនាការនោះ អ្នកអាចស្នើឲ្យតុលាការីចេញបញ្ជាអំពីគម្រោងសំណងដែលអ្នកអាចលកលៃធ្វើបាន ឬ កំណត់ថាអ្នកមិនអាចសងអ្វីទាំងអស់ក្នុងពេលនេះ។ ប្រសិនបើអ្នកស្នើសុំគម្រោងសំណង ឬ ការពន្យារពេលសងប្រាក់ សូមបំពេញទម្រង់បែបបទ *របាយការណ៍ហិរញ្ញវត្ថុរបស់កូនបំណុលនៃការវិនិច្ឆ័យ* ដែលបានភ្ជាប់មកជាមួយ, ផ្ញើឯកសារចម្លងមួយច្បាប់ទៅម្ចាស់បំណុលនៃការវិនិច្ឆ័យ និង នាំវាមកជាមួយអ្នកទៅក្នុងសវនាការ អមនឹងឯកសារទាំងឡាយដែលអ្នកមាន ទាក់ទិននឹងស្ថានភាពហិរញ្ញវត្ថុរបស់អ្នក (ឯកសារទទួលប្រាក់ពន្ធវិញ, សន្លឹកបៀវត្ស។ល។)។ អ្នកក៏អាចទទួលទម្រង់បែបបទ និង បញ្ជីនៃចំណូលដែលបានលើកលែងដោយច្បាប់ពី www.mass.gov/courts/districtcourt ឬ ការិយាល័យរបស់ស្មៀនផងដែរ។ *ប្រសិនបើតុលាការីមិនបានរៀបគម្រោងសវនាការសំណងទេ* ហើយអ្នកចង់ស្នើសុំគម្រោងសំណង ឬ ការពន្យារពេលសងប្រាក់ សូមសុំឲ្យការិយាល័យស្មៀនរៀបគម្រោងសវនាការសំណងនៅចំពោះមុខតុលាការី។ ចូរកុំរង់ចាំរហូតទាល់តែអ្នកត្រូវបានតម្រូវឲ្យមកតុលាការ បើមិនដូច្នោះទេ អ្នកនឹងទទួលខុសត្រូវចំពោះសោហ៊ុយបន្ថែម។ ម្ចាស់បំណុលនៃការវិនិច្ឆ័យអាចមិនទទួលដីកាអនុវត្តសាលក្រមក្នុងការរឹបអូស និង លក់ទ្រព្យសម្បត្តិរបស់អ្នកឡើយ រហូតទាល់តែបន្ទាប់ពីសវនាការសំណងដំបូង (ឬ ប្រសិនបើមិនបានរៀបគម្រោងសវនាការសំណងទេ គឺរហូតដល់ 30 ថ្ងៃបន្ទាប់ពីការវិនិច្ឆ័យ)។ បន្ទាប់ពីនោះ ម្ចាស់បំណុលនៃការវិនិច្ឆ័យអាចធ្វើដូច្នោះ សូម្បីតែអ្នកនឹងធ្វើការសងប្រាក់តាមពេលក៏ដោយ លុះត្រាតែអ្នកទាំងពីរយល់ព្រមថា គេនឹងមិនធ្វើដូច្នោះឡើយ ខណៈពេលអ្នកកំពុងធ្វើការសងប្រាក់។

3. **ប្តឹងសាទុក្ខទៅចៅក្រម ឬ គណៈវិនិច្ឆ័យ** *ប្រសិនបើអ្នក**មិន**មកបង្ហាញខ្លួននៅក្នុងការកាត់ក្តី*ចំពោះមុខតុលាការីទេ (នេះគេហៅថា *កំបាំងមុខ*) អ្នកមិនអាចប្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់តុលាការីអំពីបណ្តឹងរបស់ភាគីម្ខាងទៀតឡើយ។ *ប្រសិនបើអ្នក**បាន**បង្ហាញខ្លួននៅក្នុងការកាត់ក្តី*នៅចំពោះមុខតុលាការី អ្នកអាចប្តឹងសាទុក្ខសុំការកាត់ក្តីថ្មីមួយដោយចៅក្រមម្នាក់ ឬ គណៈវិនិច្ឆ័យមួយក្រុម។ ដើម្បីធ្វើដូច្នេះ ក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីអ្នកទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់តុលាការី អ្នកត្រូវតែដាក់ទម្រង់បែបបទ *បណ្តឹងសាទុក្ខរបស់ចុងចោទ* របស់អ្នក នៅការិយាល័យរបស់ស្មៀន ដោយបញ្ជាក់ថាតើអ្នកចង់បានការកាត់ក្តីដោយចៅក្រមម្នាក់ ឬ គណៈវិនិច្ឆ័យមួយក្រុម ជាមួយនឹងថ្លៃប្តឹងសាទុក្ខ $25 (ប្រាក់មិនអាចដកវិញបាន) និង ប្រាក់ធានាប្តឹងសាទុក្ខ ឬ ប្រាក់កក់ $100 (ដែលអាចដកវិញបាន ប្រសិនបើអ្នកឈ្នះក្តីក្នុងពេលប្តឹងសាទុក្ខ ឬក៏ទុកជាឥណទានសម្រាប់អ្វីដែលអ្នកជំពាក់ ប្រសិនបើអ្នកចាញ់ក្តីក្នុងពេលប្តឹងសាទុក្ខ)។ ប្រាក់ធានា ឬ ប្រាក់កក់ប្តឹងសាទុក្ខគឺច្រើនជាងនេះ ប្រសិនបើអ្នកគឺជាម្ចាស់ផ្ទះដែលត្រូវបានគេប្តឹងសម្រាប់ការប្រគល់ប្រាក់កក់នៃការជួលទីលំនៅមកវិញ។ ថ្លៃប្តឹងសាទុក្ខ និង ប្រាក់ធានាអាចត្រូវបានកាត់បន្ថយ ឬ លើកលែង ប្រសិនបើអ្នកពិតជាក្រខ្លាំង។ នៅពេលប្តឹងសាទុក្ខ ចៅក្រម ឬ គណៈវិនិច្ឆ័យនឹងធ្វើសេចក្តីសម្រេចថ្មី ប៉ុន្តែអាចយកសេចក្តីសម្រេចរបស់តុលាការីដែលបានធ្វើពីមុនមកគិតពិចារណា។

៤. **ដាក់ញត្តិសុំមោឃភាពការវិនិច្ឆ័យ** មិនថាអ្នកបានបង្ហាញខ្លួននៅក្នុងការកាត់ក្តីចំពោះមុខតុលាការី ឬក៏អត់ទេ អ្នកអាចសុំឲ្យតុលាការីធ្វើមោឃភាព (លុបចោល) ការវិនិច្ឆ័យ ប្រសិនបើអ្នកមានមូលហេតុល្អមួយ។ សំណើបែបនេះត្រូវតែធ្វើឡើងក្នុងរយៈពេលមួយឆ្នាំ លុះត្រាតែវាផ្អែកលើការមិនបានទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងតូចតាចនោះ។ ដើម្បីធ្វើសំណើដូច្នោះ សូមសុំឲ្យការិយាល័យរបស់ស្មៀនជួយអ្នកដាក់



This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

ឯកសារ និង រៀបគម្រោង *ញត្តិសុំមោឃភាពការវិនិច្ឆ័យ*។

### តើអ្នកត្រូវបានតម្រូវឲ្យស្ថិតក្នុងតុលាការដែរឬទេ សម្រាប់សវនាការសំណង?

ប្រសិនបើរឿងក្តីនេះត្រូវបានគ្រោងសម្រាប់សវនាការសំណង ហើយសំណងនៃការវិនិច្ឆ័យមិនបានធ្វើគ្រប់ចំនួន មុនកាលបរិច្ឆេទនោះទេ៖

1. **ប្រសិនបើសំណងកើតឡើងក្នុងពេលបច្ចុប្បន្ន៖** ប្រសិនបើកូនបំណុលនៃការវិនិច្ឆ័យអនុលោមតាមការបញ្ជាឲ្យសង់ប្រាក់របស់តុលាការ នោះទាំងម្ចាស់បំណុលនៃការវិនិច្ឆ័យ និង កូនបំណុលនៃការវិនិច្ឆ័យ មិនត្រូវបានតម្រូវឲ្យស្ថិតនៅក្នុងតុលាការសម្រាប់សវនាការសំណងដែលបានគ្រោងឡើយ។
1. **ប្រសិនបើសំណងមិនកើតឡើងក្នុងពេលបច្ចុប្បន្ន ឬ គ្មានការបញ្ជាឲ្យសងប្រាក់៖** ប្រសិនបើកូនបំណុលនៃការវិនិច្ឆ័យមិនអនុលោមតាមការបញ្ជាឲ្យសង់ប្រាក់របស់តុលាការ នោះទាំងម្ចាស់បំណុលនៃការវិនិច្ឆ័យ និង កូនបំណុលនៃការវិនិច្ឆ័យត្រូវតែស្ថិតនៅក្នុងតុលាការសម្រាប់សវនាការសំណងដែលបានគ្រោង។ ***ប្រសិនបើកូនបំណុលនៃការវិនិច្ឆ័យមិនមក ហើយម្ចាស់បំណុលនៃការវិនិច្ឆ័យថ្លែងក្រោមការពិន័យនៃការភូតកុហកថាកូនបំណុលនៃការវិនិច្ឆ័យមិនបានអនុលោមតាមការបញ្ជាឲ្យសងប្រាក់របស់តុលាការ នោះដោយគ្មានសេចក្តីជូនដំណឹងបន្ថែមទៀត តុលាការអាចចេញដីកាចាប់ខ្លួនខាងរដ្ឋប្បវេណី (ដីកាចាប់ខ្លួន) ដើម្បីចាប់ខ្លួនកូនបំណុលនៃការវិនិច្ឆ័យ។***



Text

This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.